# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៩៦២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកកំពង់ត្របែក នៃខេត្តព្រៃវែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ៧៣៧ គជប.សសរ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកកំពង់ត្របែក នៃខេត្តព្រៃវែង អាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

១- លោក ចូ សារូ ជាប្រធានក្រុមប្រឹក្សាស្រុក

Downloaded from http://www.khmerlaws.com

២- លោក ប៊ុល ឆន ជាសមាជិកក្រុមប្រឹក្សាស្រុក
៣- លោក ឈឹម ឆន់ ជាសមាជិកក្រុមប្រឹក្សាស្រុក
៤- លោក ម៉ៅ សារឹម ជាសមាជិកក្រុមប្រឹក្សាស្រុក
៥- លោក សៅ សំនៀង ជាសមាជិកក្រុមប្រឹក្សាស្រុក
៦- លោក ម៉ែន សុរិទ្ធី ជាសមាជិកក្រុមប្រឹក្សាស្រុក
៧- លោក ឡៀង សាខន ជាសមាជិកក្រុមប្រឹក្សាស្រុក
៨- លោក ឡាច សុខន ជាសមាជិកក្រុមប្រឹក្សាស្រុក
៩- លោក ញ៉ើម ឈុំសារ៉ា ជាសមាជិកក្រុមប្រឹក្សាស្រុក
១០- លោក ទ្រាប ស៊ិន ជាសមាជិកក្រុមប្រឹក្សាស្រុក
១១- លោក ម៉េត សាត ជាសមាជិកក្រុមប្រឹក្សាស្រុក
១២- លោក ហង់ សារ៉ែន ជាសមាជិកក្រុមប្រឹក្សាស្រុក
១៣- លោកស្រី ហង្ស ថាន ជាសមាជិកក្រុមប្រឹក្សាស្រុក
១៤- លោក ជា នួច ជាសមាជិកក្រុមប្រឹក្សាស្រុក
១៥- លោក ឡុង ផារី ជាសមាជិកក្រុមប្រឹក្សាស្រុក
១៦- លោក ម៉ែន សំឡូន ជាសមាជិកក្រុមប្រឹក្សាស្រុក
១៧- លោក យោគ យ៉េង ជាសមាជិកក្រុមប្រឹក្សាស្រុក
១៨- លោក ឃឹម សំអឿន ជាសមាជិកក្រុមប្រឹក្សាស្រុក
១៩- លោក ផន សុត ជាសមាជិកក្រុមប្រឹក្សាស្រុក ។

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកកំពង់បែក នៃខេត្តព្រៃវែង ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ [illegible] ឆ្នាំ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត* (<u>ដើម្បីជូនជ្រាប</u>)
- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ*

Downloaded from http://www.khmerlaws.com